Article 5 of the LOSC provides as follows: Except where otherwise provided in this Convention, the normal baseline for measuring the breadth of the territorial sea is the low-water line along the coast as marked on large-scale charts officially recognized by the coastal State. The ICJ, in the 1951 Anglo-Norwegian Fisheries case, stated: [F]or the purpose of measuring the breadth of the territorial sea, it is the low-water mark as opposed to the high-water mark, or the mean between the two tides, which has generally been adopted in the practice of States. This criterion is the most favorable to the coastal State and clearly shows the character of territorial waters as appurtenant to the land territory **(Yoshifumi Tanaka, the International Law of the Sea, 3rd Ed., 2019, p. 54; ICJ Reports 1951, p. 128)**

មាត្រា៥នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (LOSC) លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងអនុសញ្ញានេះ ខ្សែបន្ទាត់មូលដ្ឋានធម្មតាសម្រាប់វាស់ទទឹងសមុទ្រដែនដី គឺខ្សែបន្ទាត់ទឹកនាច (low-water line) នៅតាមបណ្តោយឆ្នេរសមុទ្រ ដូចដែលបានសម្គាល់នៅលើផែនទីខ្នាតធំ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋឆ្នេរសមុទ្រ។ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅក្នុងសំណុំរឿងនេសាទត្រីរវាងអង់គ្លេស-ន័រវេសឆ្នាំ១៩៥១ បានបញ្ជាក់ថា៖ «សម្រាប់គោលបំណងនៃការវាស់ទទឹងសមុទ្រដែនដី គឺចំណុចសម្គាល់កន្លែងទឹកនាច (មិនមែនចំណុចសម្គាល់កន្លែងទឹកឡើងឬកម្រិតមធ្យមរវាងជំនោរទាំងពីរ) ដែលត្រូវបានទទួលយកជាទូទៅក្នុងការអនុវត្តរបស់រដ្ឋនានា»។ លក្ខណៈវិនិច្ឆ័យនេះគឺអំណោយផលបំផុតសម្រាប់រដ្ឋឆ្នេរសមុទ្រ ហើយបង្ហាញយ៉ាងច្បាស់អំពីលក្ខណៈនៃដែនទឹកតភ្ជាប់នឹងដែនដី។